S-PN-2

# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងក្រុងភ្នំពេញ

-សំណុំរឿងព្រហ្មទណ្ឌ
លេខ ១២០៧
ចុះថ្ងៃទី២១/០៧/២០០៧
-សាលក្រមលេខ ២២ "ក្រ២"
ចុះថ្ងៃទី១៩/០៣/២០០៨

## តាងនាមប្រជារាស្ត្រខ្មែរ

សាលាដំបូងក្រុងភ្នំពេញ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលា ជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រិត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅនាទីសាលាដំបូងក្រុងភ្នំពេញនៅ ថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០៨ ដោយមានសមាសភាពចូលរួមដូចតទៅ :

**<u>ក្រុមប្រឹក្សាជំនុំជំរះ</u>**

-លោក [redacted] អនុប្រធានសាលាដំបូងក្រុងភ្នំពេញ ជាប្រធានក្រុមប្រឹក្សាជំនុំជំរះ

-លោក [redacted] ចៅក្រមសាលាដំបូងក្រុងភ្នំពេញ ជាសមាជិក

-លោក [redacted] ចៅក្រមសាលាដំបូងក្រុងភ្នំពេញ ជាសមាជិក

**<u>តំណាងអយ្យការ</u>**

-លោក [redacted] ព្រះរាជអាជ្ញារង អមសាលាដំបូងក្រុងភ្នំពេញ

**<u>ក្រឡាបញ្ជីសវនាការ</u>**

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងក្រុងភ្នំពេញ

**<u>ដើម្បីជំនុំជំរះ</u>** សំណុំរឿងព្រហ្មទណ្ឌលេខ ១២០៧ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៧ ជនជាប់ចោទ :

-ឈ្មោះ [redacted] ជាន់ជាណោ ភេទប្រុស អាយុ ២៥ ឆ្នាំ ជាតិខ្មែរ កើតនៅសង្កាត់ផ្សារកណ្តាល ខណ្ឌដូនពេញ រាជធានីភ្នំពេញ កាន់សាសនាព្រះពុទ្ធ មានទីលំនៅសព្វថ្ងៃ [redacted] ខណ្ឌឬស្សីកែវ រាជធានីភ្នំពេញ របររកស៊ីមិនពិតប្រាកដ ប្រពន្ធឈ្មោះ [redacted] មានកូន ៣ នាក់ ឪពុកឈ្មោះ[redacted] "ស" ម្តាយឈ្មោ[redacted] "ស" ទោសពីមុនគ្មាន ។

-ជាប់ចោទពីបទ ប្លន់ ប្រព្រឹត្តនៅ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ[redacted]សុភាព ភេទស្រី អាយុ ២១ឆ្នាំ ជាតិខ្មែរ មានទីលំនៅផ្ទះលេខ ១០៣ ផ្លូវលេខ ១៣៤ ក្រុមទី៦ សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។

-មេធាវី លោ[redacted] ការពារជនត្រូវចោទឈ្មោះ[redacted] ជាន់ជាណោ ។

**<u>ការប្រព្រឹត្តរបស់ជនត្រូវចោទមានដូចតទៅ</u>** :



Scanned by CamScanner

124/04

កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោងដប់បួន នៅចំនុចមុខផ្ទះលេខ៧៣ បេសេអីស្វូឡ ផ្លូវម៉ៅសេទុង សង្កាត់ផ្សារដេប៉ូទី២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ជនល្មើសឈ្មោះ [redacted] ជាន់ដាណេ បានធ្វើសកម្មភាពលួចចាក់កាច់សោរម៉ូតូ គុបសេ ៥០ ពណ៌ខៀវ ចង្កៀងជ្រុង ដោយប្រើប្រដាប់កាច់សោរ និងកូនសោរលេខ ៨ កាច់បំបែកគ្រាប់សោររបស់ជនរងគ្រោះឈ្មោះ [redacted]សុភាព ។ បន្ទាប់ពីយកម៉ូតូនោះហើយ ជនល្មើសបានយកទៅលក់ឱ្យឈ្មោះ ខូច បានតំលៃ ៣៥០ ដុល្លា ។

-បានឃើញ របាយការណ៍សំយោគលេខ ១១៧/របក ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ២០០៧ របស់អធិការនគរបាលខណ្ឌទួលគោក ។

-បានឃើញ របាយការណ៍ស្តីពី ករណីចោរលួចម៉ូតូគុបជ្រុងពណ៌ខៀវ ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧ របស់នគរបាលប៉ុស្តិ៍ផ្សារដេប៉ូទី ២ ។

-បានឃើញ ពាក្យបណ្តឹងរបស់ឈ្មោះ [redacted] សុភាព ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧ ។

-បានឃើញ កំណត់ហេតុសួរចំលើយជនរងគ្រោះឈ្មោះ [redacted] សុភាព ចុះថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧ នៅនគរបាលប៉ុស្តិ៍ផ្សារដេប៉ូទី ២ ។

-បានឃើញ កំណត់ហេតុសួរចំលើយឈ្មោះ [redacted] ជាន់ដាណេ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០០៧ នៅអធិការដ្ឋាននគរបាលខណ្ឌទួលគោក ។

-បានឃើញ កំណត់ហេតុសួរចំលើយឈ្មោះ [redacted] ជាន់ដាណេ ចុះថ្ងៃទី២១ ខែកក្កដា ឆ្នាំ២០០៧ នៅអយ្យការអមសាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញ កំណត់ហេតុសួរចំលើយឈ្មោះ [redacted] ជាន់ដាណេ ថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ២០០៧ នៅចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញ កំណត់ហេតុសួរចំលើយជនរងគ្រោះឈ្មោះ [redacted] សុភាព ចុះថ្ងៃទី ៣ ខែ សីហា ឆ្នាំ ២០០៧ នៅចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ១៤៥៥ អយយ ចុះថ្ងៃទី ០៧ ខែ វិច្ឆិកា ឆ្នាំ ២០០៧ របស់ព្រះរាជអាជ្ញា សាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញ ដីកាបញ្ជូនរឿងទៅជំនុំជំរះលេខ ៨៥៥៩ តព្រ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ ។

-បានឃើញ ដីកាចាត់តាំងក្រុមព្រឹក្សាជំនុំជំរះលេខ ២៤២០ តព្រ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ប្រធានសាលាដំបូងក្រុងភ្នំពេញ ។

## នាពេលសវនាការ

-តំណាងអយ្យការបានធ្វើការចោទប្រកាន់លើឈ្មោះ [redacted] ជាន់ដាណេ ពីបទ ប្លន់ប្រព្រឹត្តទៅសង្កាត់



Scanned by CamScanner

ផ្សារដេរប៉ូ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ តាមមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ ។

ស.ឆ ជនជាប់ចោទឈ្មោះ [redacted] **ជាន់ដារ៉ាណេ** បានឆ្លើយថា ខ្លួនពិតជាបានយកម៉ូតូ ១គ្រឿង នៅចំនុចផ្ទះលេខ៧៣ បេ សេ អឺ សូន្យ ផ្លូវម៉ៅសេទុង សង្កាត់ផ្សារដេរប៉ូ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ ។ ខ្លួនបានប្រើប្រដាប់កាច់សោរម៉ូតូ និងកូនសោរលេខ៨ កាច់បំបែកគ្រាប់សោរកម៉ូតូ ខ្លួនធ្វើសកម្មភាពតែម្នាក់ឯង ។

-ចៅក្រមបានឱ្យក្រឡាបញ្ជី អានចំលើយដើមបណ្តឹងឈ្មោះ [redacted] **សុភាព** នៅចៅក្រមស៊ើបសួរសាលាដំបូងក្រុងភ្នំពេញ និងរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ដែលមានខ្លឹមសារដូចតទៅ: តាមចម្លើយដើមបណ្តឹងឈ្មោះ [redacted] **សុភាព** នៅចៅក្រមស៊ើបសួរតុលាការក្រុងភ្នំពេញ បានឆ្លើយថា នៅថ្ងៃទី២៧ ខែមិថុនា ឆ្នាំ២០០៧ វេលាម៉ោង១១ និង៣០នាទី ខ្ញុំបានមកពីរៀន បានយកម៉ូតូម៉ាក់សេ៥០ជ្រុង ពណ៌ខៀវ ទុកនៅមុខហាងកែសម្ផស្សល្អពិត លេខ ៣៧៣ បេ អឺ សូន្យ ដោយចាក់សោរកត្រឹមត្រូវហើយខ្ញុំក៏ឡើងទៅលើផ្ទះ លុះមកដល់ម៉ោងប្រហែលពីរជាង ខ្ញុំចុះមកយកម៉ូតូបំរុងយកទៅរៀនស្រាប់តែមិនឃើញម៉ូតូតែម្តង ខ្ញុំទិញម៉ូតូតំលៃ៩០០ដុល្លា លុះមកដល់ថ្ងៃទី១៩ ខែកក្កដា ឆ្នាំ២០០៧ ត្រូវសមត្ថកិច្ចចាប់ជនល្មើសបាន ពេលនោះជនល្មើសបានឆ្លើយសារភាពថា ខ្លួនពិតជាបានលួចម៉ូតូ របស់ខ្ញុំមែននៅមុខផ្ទះកែសម្ផស្សល្អពិត កាលពីថ្ងៃទិ២៧ ខែមិថុនា ឆ្នាំ២០០៧ សំណូមពរសុំឱ្យតុលាការផ្តន្ទាទោសជនល្មើសតាមច្បាប់ សុំទាមទារសំណងម៉ូតូគ្រប់ចំនួនវិញ សុំទាមទារជំងឺចិត្ត ២០០ ដុល្លា ។ តាមរបាយការណ៍ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ថា ចម្លើយសារភាពរបស់ជនល្មើសឈ្មោះ [redacted] **ជាន់ដារ៉ាណេ** បានសារភាពថា ខ្លួនពិតជាបានធ្វើសកម្មភាពលួចម៉ូតូ របស់ជនរងគ្រោះ ពិតប្រាកដមែន ក្នុងការធ្វើសកម្មភាពខ្លួនធ្វើតែម្នាក់ឯងពុំមានបក្សពួកទេ ដោយជិះម៉ូតូឌុបមកដល់ ឃើញម៉ូតូរបស់ជនរងគ្រោះ ក៏ធ្វើសកម្មភាពលួចតែម្តង ដោយប្រើឧបករណ៍ដែកសំប៉ែត សំរាប់កាច់បំបែកគ្រាប់សោរម៉ូតូរបស់ជនរងគ្រោះ ។ ក្រោយពេលលួចម៉ូតូរបស់ជនរងគ្រោះបានហើយ ខ្លួនបានយកទៅលក់ឱ្យឈ្មោះ **ទូច** ភេទប្រុស អាយុប្រហែល ៣៥ ឆ្នាំ ស្នាក់នៅផ្ទះជួល សង្កាត់បឹងកក់ទី២ ខណ្ឌទួលគោក បានតំលៃ ៣៥០ ដុល្លាអាមេរិក ។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា ជនជាប់ចោទបានឆ្លើយសារភាពថាខ្លួនបានយកប្រដាប់កាច់សោរកម៉ូតូ កាច់សោរកម៉ូតូរបស់ជនរងគ្រោះ នៅចំនុចផ្លូវម៉ៅសេទុង ផ្ទះលេខ ៧៣ បេ សេ អឺ សូន្យ សង្កាត់ផ្សារដេរប៉ូ ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ នេះជាភស្តុតាងដែលមានលក្ខណៈគ្រប់គ្រាន់ ដូច្នេះក្នុងនាមតំណាងអយ្យការ សុំតំកល់ការចោទប្រកាន់ និងសុំលោកចៅក្រម សំរេចសេចក្តីតាមច្បាប់ ។

-មេធាវីការពារជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានសារភាពពីអំពើរបស់គេហើយខ្លួនមេធាវីការពារសំណូមពរ សុំឱ្យលោកចៅក្រមបន្ធូរបន្ថយទោសដល់គេផង ។

ស.ឆ ជនជាប់ចោទឈ្មោះ [redacted] **ជាន់ដារ៉ាណេ** បានឆ្លើយសំដីចុងក្រោយបង្ហស់ថា ខ្លួនសុំឱ្យតុលាការ—



Scanned by CamScanner

បន្ធូបន្ថយទោសផង ។

-ក្រោយពីបានស្តាប់ ចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់ ការអានចម្លើយ ដើមបណ្តឹង

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់ សេចក្តីសន្និដ្ឋាន របស់មេធាវីការពារជនជាប់ចោទ

-ក្រោយពីបានស្តាប់ សំដីចុងក្រោយ របស់ជនជាប់ចោទ

ក្រោយពីបាន ពិនិត្យពិចារណា ត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការក្រុងភ្នំពេញ

## យល់ឃើញថា

-ចម្លើយជនជាប់ចោទឈ្មោះ [redacted]**ជាន់ជាណេ** ឆ្លើយថា ពិតជាបានប្រើប្រដាប់កាច់សោរកម៉ូតូ និងកូនសោរលេខ ៨ កាច់បំបែកគ្រាប់សោរកម៉ូតូ និងលួចយកបានម៉ូតូនៅចំនុចផ្ទះលេខ៧៣ បេ សេ អឺ សូឡផ្លូវម៉ៅសេទុង សង្កាត់ផ្សារដេរប៉ូទី២ ខណ្ឌទួលគោក និងបានយកម៉ូតូទៅលក់ឱ្យឈ្មោះ **ទូច** ១ បានចាត់ចែងលក់បន្ត មានលក្ខណៈច្បាស់លាស់ មានភស្តុងតាងត្រឹមត្រូវតាមច្បាប់ អាចឱ្យពិចារណាបាន ។

-តាមចម្លើយជនជាប់ចោទ.ចម្លើយដើមបណ្តឹង.វត្ថុតាងដែលដកហូតបានពីជនជាប់ចោទ និងរបាយការណ៏ស៊ើបអង្កេតរបស់មន្ត្រីនគរបាលយុត្តិធម៌ ជាភស្តុតាងដាក់បន្ទុកដែលមានលក្ខណៈគ្រប់គ្រាន់ និងស៊ីសង្វាក់គ្នា អាចកំណត់បានថា នៅថ្ងៃកើតហេតុថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០០៧ ជនជាប់ចោទឈ្មោ[redacted] **ជាន់ជាណេ** បានប្រើប្រាស់ប្រដាប់កាច់សោរកម៉ូតូ និងកូនសោរលេខ៨កាច់បំបែកគ្រាប់សោរម៉ូតូរបស់ដើមបណ្តឹងឈ្មោះ [redacted]**សុភាព** ដែលដាក់នៅមុខផ្ទះ លួចយកបានម៉ូតូហើយ យកទៅលក់ឱ្យឈ្មោះ **ទូច** គ្មានសាវតាជាតិ បានប្រាក់យកទៅចាត់ចែង ជាប្រយោជន៍ផ្ទាល់ខ្លួន ជាការប្រព្រឹត្តអំពើលួច ដោយមានស្ថានទំងន់ទោស កំណត់តាមច្បាប់ ជាប្រព្រឹត្តបទ ប្លន់ ដូចមានចែងនិងត្រូវផ្តន្ទាទោសតាមម៉ាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted]**ជាន់ជាណេ** ពីបទ ប្លន់ ប្រព្រឹត្តនៅសង្កាត់ផ្សារដេប៉ូទី ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ កាលពីថ្ងៃទី ២៧ ខែមិថុនា ឆ្នាំ ២០០៧

បទល្មើសព្រហ្មទណ្ឌដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា៦នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

-គប្បីពិនិត្យសំរេចដល់សំណងរដ្ឋប្បវេណី ដោយដើមបណ្តឹងទាមទារសុំតាមច្បាប់ ។

-សេចក្តីសន្និដ្ឋាន របស់តំណាងអយ្យការពេលសវនាការ សន្និដ្ឋានបញ្ជាក់ពីពិរុទ្ធភាព លើជនជាប់ចោទ និងសុំតំកល់ការចោទប្រកាន់ មានលក្ខណៈត្រឹមត្រូវតាមច្បាប់ ។



Scanned by CamScanner

24/01

-សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ បានស្នើសុំឱ្យបន្ធូបន្ថយទោសដល់កូនក្តី ។

**ហេតុដូច្នេះ**

**សំរេច**

១/ផ្តន្ទាទោសលើឈ្មោះ [redacted]**ជាន់ដាណេ** ភេទប្រុស អាយុ ២៥ឆ្នាំ ដាក់ពន្ធនាគារកំណត់ ៥ ឆ្នាំ គិតបន្តពីសាលក្រមមុន

ពីបទប្លន់ ប្រព្រឹត្តនៅសង្កាត់ផ្សារដេប៉ូ២ ខណ្ឌទួលគោក ក្រុងភ្នំពេញ កាលពីថ្ងៃទី២៧ ខែមិថុនា ឆ្នាំ ២០០៧

បទល្មើសព្រហ្មទណ្ឌដែលមានចែង និងត្រូវផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៦ នៃច្បាប់ស្តីពីស្ថានទំងន់ទោសនៃបទឧក្រិដ្ឋ ។

២/ឱ្យឈ្មោះ [redacted]**ជាន់ដាណេ** សងទៅឈ្មោះ [redacted] **សុភាព** ជាដើមបណ្តឹង នូវសំណងថ្លៃម៉ូតូ ម៉ាក់ ហុង ដា ធុន គុប សេ ៥០ ចង្កៀង ជ្រុង ចំនួនមួយគ្រឿង គិតជាប្រាក់រៀលស្មើ និងប្រាក់អាមេរិក ចំនួន ៩០០ " ប្រាំបួនរយដុល្លា " និងសងសំណងជំងឺចិត្ត គិតជាប្រាក់រៀលស្មើនឹងប្រាក់អាមេរិកចំនួន ២០០ ដុល្លា " ពីររយ ដុល្លា " ។

៣/សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី ។

ទុករយៈពេលប្តឹងទាស់ និងបើងផ្លូវប្តឹងឧទ្ធរណ៍ តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ** | **សមាជិក** | **ប្រធានក្រុមប្រឹក្សាជំនុំជំរះ**

[redacted] [redacted] [redacted]

[redacted]



Scanned by CamScanner